# របាយការណ៍ស្ទង់មតិ

## ការរាយការណ៍របស់កុមារអំពីស្ថានភាពនៃ ការប្រើប្រាស់គ្រឿងញៀនក្នុងសហគមន៍

ក្រុមយុវជនស្ម័គ្រចិត្ត

សម្របសម្រួលដោយ

Good Neighbors Cambodia

ខែ សីហា ឆ្នាំ ២០១៩

# ក្រុមប្រឹក្សាយោបល់

លោក **វ.ទោ យិន យឿត** អនុប្រធាននាយកដ្ឋាននីតិកម្ម អប់រំ និងស្តារនីតិសម្បទា នៃ អគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

លោក **ឆម មុនី** ប្រធានផ្នែកប្រតិបត្តិ អង្គការហ្វូដណេប៊ីសកម្ពុជា

លោក **ឡុង ផានិត** មន្ត្រីសម្របសម្រួលតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

# ក្រុមត្រួតពិនិត្យ

កញ្ញា នាង សុភី

កញ្ញា ផេង សិទ្ធី

លោក យឿន ដារ៉ា

លោក ហម សៃយ៉ាន់

លោក សុខ ឌូ

លោក ឆេង សាមុត

អ្នកស្រី ចេវ ស្រីប៉ាង

លោក នូ ភីរម្យ

លោក សេក សាវ៉ាន់

លោក វួន សាវុធ

លោក អ៊ុយ សុផល

# ក្រុមសរសេររបាយការណ៍

កញ្ញា នូវ ស៊ីវន

កញ្ញា គុន ស្រីទៀង

កញ្ញា ព្រិច ផាច

លោក រិន ទិត្យារក្ស

លោក ឃី ឧត្តម

កញ្ញា ផូ ម៉ូលីសា

កញ្ញា វ៉ា វ៉ាន់

កញ្ញា ផាត សុភ័ស្ត

កញ្ញា រិន ណងគា

កញ្ញា យៀង ចន្ទកនិកា

កញ្ញា អាន សុខស្រីលាភ

# មាតិកា


លិខិតថ្លែងអំណរគុណ ..... 3

បញ្ជីរូបភាព ..... 4

១. សេចក្តីផ្តើម ..... 6

២. គោលបំណងនៃការស្ទង់មតិ ..... 8

៣. វិធីសាស្ត្រនៃការស្ទង់មតិ ..... 8

៤. វិសាលភាព និងដែនកំណត់ ..... 10

៥. លទ្ធផលនៃការស្ទង់មតិ ..... 10

 ៥.១ ព័ត៌មានទូទៅ ..... 10

 ៥.២. ការយល់ដឹងពីគ្រឿងញៀន ..... 11

 ៥.៣: ការអង្កេតអំពីការប្រើប្រាស់គ្រឿងញៀនក្នុងរយៈពេល ១២ ខែចុងក្រោយ ..... 12

 ៥.៤. សុវត្ថិភាពកុមារ ..... 13

 ៥.៥. កិច្ចអន្តរាគមន៍ ..... 15

៦. សេចក្តីសន្និដ្ឋាន ..... 16

៧. សំណូមពរ ..... 16

៨. ឯកសារភ្ជាប់ ..... 18

# លិខិតថ្លែងអំណរគុណ

យើងខ្ញុំដែលជាក្រុមយុវជនមានសេចក្ដីរំភើប និងរីករាយយ៉ាងខ្លាំងដែលបានទទួលនូវឱកាសសិក្សារៀនសូត្រ និងចូលរួមសកម្មភាពផ្សេងៗដើម្បីបង្កើនចំណេះដឹង និងបទពិសោធន៍។ យើងខ្ញុំសូមថ្លែងអំណរគុណដល់អង្គការហ្វូដណោប៊ឺសកម្ពុជា ដែលបានផ្ដល់ឱកាសនេះដល់ក្រុមយុវជនយើងខ្ញុំបានចូលរួមក្នុងសិក្ខាសាលាស្ដីអំពីការចូលរួមរបស់កុមារ និងយុវជនដើម្បីទប់ស្កាត់ និងប្រយុទ្ធប្រឆាំងគ្រឿងញៀន រួមទាំងផ្ដល់បច្ចេកទេសនិងគាំទ្រដល់ពួកយើងដើម្បីអាចរៀបចំធ្វើការស្ទង់មតិនេះឡើង។ ពួកយើងពិតជាទទួលបានចំណេះដឹងថ្មីៗ បទពិសោធន៍ល្អៗ ទទួលបាន ជួយឧបត្ថម្ភគាំទ្រដើម្បីអោយស្គាល់តំបន់ផ្សេងៗ ថែមទាំងបានស្គាល់ក្រុមយុវជនមកពីខេត្តផ្សេងទៀតផង។

សូមអរគុណចំពោះ លោកនាយក លោកស្រីនាយិកា និងលោកគ្រូ-អ្នកគ្រូ ដែលបានអនុញ្ញាតឱ្យយើងខ្ញុំបានចុះជួប និងសម្ភាសន៍កុមារនៅក្នុងសាលារៀនដអំពីការយល់ដឹង បទពិសោធន៍ និងការព្រួយបារម្ភរបស់ពួកគេអំពីបញ្ហាគ្រឿងញៀន។

សូមអរគុណដល់អាជ្ញាធរមូលដ្ឋានដែលមានមេភូមិ និងក្រុមប្រឹក្សឃុំដែលបានអនុញ្ញាតឱ្យពួកយើងអាចជួប និងសម្ភាសន៍កុមារក្នុងសហគមន៍អំពីគ្រឿងញៀន។

សូមអរគុណចំពោះ អាណាព្យាបាលកុមារទាំងអស់ដែលបានអនុញ្ញាតអោយយើងខ្ញុំជាក្រុមយុវជនបានជួបសម្ភាសន៍កូនៗ និងបង្ករបរិយាកាសរីករាយ។

ជាចុងក្រោយ សូមជូនពរបុគ្គលិកអង្គការហ្វូដណោប៊ឺសកម្ពុជា លោកនាយក នាយិការ លោកគ្រូអ្នកគ្រូ អាជ្ញាធរមូលដ្ឋាន ឪពុកម្ដាយ និងអាណាព្យាបាលទាំងអស់មានសុខភាពល្អ កំលាំងមាំមួន និងជោគជ័យគ្រប់ភារកិច្ច។

# បញ្ជីរូបភាព


រូបភាពទី 1: សំណាកកុមារចូលរួមសម្ភាសន៍នៅតាមតំបន់នីមួយៗ ........................................ 11
រូបភាពទី 2: ប្រភពព័ត៌មានសំខាន់ៗដែលផ្សព្វផ្សាយអំពីគ្រឿងញៀន ........................................ 11
រូបភាពទី 3: ផលប៉ះពាល់នៃគ្រឿងញៀន ........................................ 12
រូបភាពទី 4:  កុមារធ្លាប់ឃើញការប្រើប្រាស់គ្រឿងញៀនក្នុងសហគមន៍ ........................................ 12
រូបភាពទី 5: ក្រុមអាយុអ្នកប្រើប្រាស់គ្រឿងញៀនក្នុងសហគមន៍ ........................................ 13
រូបភាពទី 6:កុមាររងផលប៉ះពាល់ដោយសារចរាចរ និងការប្រើគ្រឿងញៀនក្នុងសហគមន៍ ........................................ 14
រូបភាពទី 7: កុមារធ្លាប់ត្រូវគេណែនាំ លួងលោម ឬ បង្ខំឱ្យប្រើប្រាស់គ្រឿងញៀន ........................................ 14
រូបភាពទី 8: អាជ្ញាធរមូលដ្ឋានចុះអប់រំ និងផ្សព្វផ្សាយអំពីផលប៉ះពាល់នៃគ្រឿងញៀន ........................................ 15

# មូលន័យសង្ខេប

កម្ពុជាបានក្លាយជាប្រទេសរងគ្រោះដោយសារការកើនឡើង និងការហូរចូលគ្រឿងញៀនតាមច្រកព្រំដែន និងតាមបណ្តោយទន្លេមេគង្គ ដែលនេះ បានធ្វើអោយប៉ះពាល់ខ្លាំងដល់ការអភិវឌ្ឍធនធានមនុស្ស សេដ្ឋកិច្ច និងសង្គម។ ប្រជាជនកម្ពុជា ដោយរួមទាំងកុមារ យុវជន និងមនុស្សពេញវ័យ ត្រូវបានមើលឃើញថា បានរងគ្រោះដោយផ្ទាល់ និងប្រយោល ដែលតាមការស្រាវជ្រាវបានបញ្ជាក់ថា អ្នកប្រើប្រាស់គ្រឿងញៀនភាគច្រើនជា យុវជន និងមនុស្សពេញវ័យ ដែលមានអាយុចន្លោះពី ១៨ ដល់ ៣៥ ឆ្នាំ។ ស្របពេលជាមួយគ្នានេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលការណ៍នានា រួមទាំងបង្កើតក្រុមការងារអន្តរក្រសួងដើម្បីទប់ស្កាត់ និងប្រយុទ្ធប្រឆាំងគ្រឿងញៀន។

ការស្ទង់មតិនេះ ត្រូវបានធ្វើឡើងក្នុងគោលបំណងសិក្សាអំពីស្ថានភាព និងផលប៉ះពាល់នៃគ្រឿងញៀនលើកុមារក្នុងសហគមន៍ពាក់ព័ន្ធនឹងការយល់ដឹង សុវត្ថិភាព ការព្រួយបារម្ភ និងសំណូមពររបស់ពួកគេដើម្បីស្វែងរកកិច្ចអន្តរាគមន៍ទាន់ពេលវេលា។ បន្ទាប់ពីទទួលបានវគ្គបណ្តុះបណ្តាល ក្រុមយុវជនស្ម័គ្រចិត្តប្រមាណ ៤០នាក់បានរៀបចំកម្រងសំណួរ និងចុះសម្ភាសន៍កុមារទាំងក្នុងសាលារៀន និងសហគមន៍ចំនួន ២៨៣នាក់ ស្ថិតក្នុង ៨១ភូមិ ១៩ឃុំ-សង្កាត់ និង ៧ស្រុក-ខណ្ឌ នៃរាជធានីភ្នំពេញ ខេត្តបន្ទាយមានជ័យ បាត់ដំបង ក្រចេះ និងមណ្ឌលគិរី។ លទ្ធផលនៃការសិក្សានេះបានបង្ហាញថា វត្តមាននៃគ្រឿងញៀនបានសាយភាយដល់សហគមន៍ដាច់ស្រយ៉ាល ហើយកុមារភាគច្រើនបានរាយការណ៍ថា ពួកគេបានឃើញការជួញដូរ និងប្រើប្រាស់គ្រឿងញៀនក្នុងសហគមន៍របស់ពួកគេ។ ស្ទើរតែទាំងអស់នៃកុមារដែលចូលរួមក្នុងកិច្ចសម្ភាសន៍បានបង្ហាញថា គ្រឿងញៀនពិតជាបានប៉ះពាល់យ៉ាងខ្លាំងដល់សុវត្ថិភាព សុខភាព និងការអប់រំរបស់ពួកគេ។ កុមារមួយចំនួនធ្លាប់ត្រូវបានគេណែនាំ និងលួងលោមអោយប្រើប្រាស់គ្រឿងញៀន និងកុមារខ្លះទៀតធ្លាប់ប្រើប្រាស់គ្រឿងញៀន។ អ្នកប្រើប្រាស់គ្រឿងញៀនបានបង្កអោយមានបញ្ហាអសន្តិសុខ អំពើលួចប្លន់ អត្តឃាត អំពើហឹង្សា និងបែកបាក់គ្រួសារជាដើម។ សម្រាប់កុមារផ្ទាល់ ពួកគេពិតជាមានការភ័យខ្លាច ទោះបីជានៅផ្ទះម្នាក់ឯង ការធ្វើដំណើរទៅទីកន្លែងផ្សេង ការទៅសាលារៀន និងចូលរួមសកម្មភាពផ្សេងៗក្នុងសហគមន៍។ នេះបង្ហាញថា គ្រឿងញៀនបានបង្កផលប៉ះពាល់ដល់សុវត្ថិភាព សុខភាព ការអប់រំ និងការអភិវឌ្ឍកុមារ និងយុវជនកម្ពុជា ដែលតម្រូវអោយមានកិច្ចអន្តរាគមន៍ និងទប់ស្កាត់ជាបន្ទាន់ពីសំណាក់អាជ្ញាធរមូលដ្ឋាន រាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធ ដើម្បីជាប្រយោជន៍សម្រាប់កុមារ ប្រជាជន និងសង្គមជាតិទាំងមូល។

# ១. សេចក្តីផ្តើម

ប្រទេសកម្ពុជាមិនមែនស្ថិតក្នុងតំបន់ត្រីកោណមាស ដែលជាប់ពាក់ព័ន្ធនឹងការផលិតគ្រឿងញៀនទេ ប៉ុន្តែការជួញដូរគ្រឿងញៀននៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ឆ្លងកាត់ទន្លេមេគង្គ និងព្រំដែនពីប្រទេសថៃ ឡាវ និងវៀតណាមចូលក្នុងប្រទេសកម្ពុជា គឺជាដើមចមដ៏សំខាន់ដែលធ្វើឱ្យលំហូរគ្រឿងញៀនមានការកើនឡើងចូលក្នុងប្រទេសកម្ពុជា[1]។ ការកើនឡើងនៃគ្រឿងញៀនបានក្លាយជាបញ្ហាប្រឈមដ៏ធំមួយដែលរាំងស្ទះដល់ឱកាសទទួលបានការអប់រំ គុណភាពការសិក្សារបស់សិស្ស ការអភិវឌ្ឍយុវជន និងសង្គមកម្ពុជា ខណៈដែលរាជរដ្ឋាភិបាលកម្ពុជាមានមហិច្ឆិតាអភិវឌ្ឍប្រទេស ឱ្យមានការផ្លាស់ប្តូរពីប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាបទៅជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងជាប្រទេសអភិវឌ្ឍន៍នៅឆ្នាំ ២០៥០។

តាមរយៈបទបញ្ជាលេខ ០១ ប ប ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការពង្រឹងវិធានការប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបង្ហាញពីការព្រួយបារម្ភរបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះការកើនឡើងនៃបញ្ហាគ្រឿងញៀន ដោយបានដាក់ចេញនូវគោលការណ៍ដ៏តឹងរឹងដើម្បីទប់ស្កាត់ និងប្រយុទ្ធប្រឆាំងគ្រឿងញៀននៅក្នុងប្រទេសកម្ពុជា[2]។ ក្នុងផែនការជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ ២០១៦-២០១៨ បានបង្ហាញពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងគ្រឿងញៀនដើម្បីសុវត្ថិភាព និងការអភិវឌ្ឍនៅកម្ពុជា។ ផែនការយុទ្ធសាស្ត្រដែលមាន ៨ ចំនុចសំខាន់ៗ បានសង្កត់ធ្ងន់លើកិច្ចសហការអន្តរក្រសួងដើម្បីអន្តរាគមន៍ និងប្រយុទ្ធប្រឆាំងគ្រឿងញៀន ដោយរួមសរុបមកមានក្រសួងសំខាន់ៗចំនួន ១៣។ ផែនការណែនាំស្តីពីការចាត់តាំងអនុវត្តគោលនយោបាយ "ភូមិ ឃុំមានសុវត្ថិភាព" ដែលបានបង្កើតឡើងដែលលក្ខណៈសម្បត្តិ ៩យ៉ាង ក៏បានសង្កត់ធ្ងន់មិនអោយមាន "ការដាំដុះ ការផលិត ការចរាចរ ការជួញដូរ ការចែកចាយ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់" ។ យ៉ាងណាក្តី ប្រជាពលរដ្ឋខ្មែរ ជាពិសេសកុមារ និងយុវជននៅតែខ្លាច និងរងផលប៉ះពាល់ពីបញ្ហាគ្រឿងញៀនដែលកើតឡើងទាំងនៅរាជធានីភ្នំពេញ តាមបណ្តាខេត្ត និងនៅតាមសហគមន៍នានា។

---

[1] របាយការប្រចាំត្រីមាសទី៣ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

2 អាជ្ញាធរជាតិ សហការជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តសៀមរាប ប្រារព្ធទិវា អន្តរជាតិ ប្រយុទ្ធប្រឆាំង គ្រឿងញៀន(www.nacd.gov.kh)

យោងតាមការចុះផ្សាយរបស់អគ្គស្នងការនគរបាលជាតិបានឲ្យដឹងថា យុទ្ធនាការបង្ក្រាបគ្រឿងញៀនក្នុងរយៈពេល៦ខែ ដើមឆ្នាំ២០១៩នេះ អាជ្ញាធរបានបង្ក្រាបបទល្មើសគ្រឿងញៀនបានចំនួន ៣ ៦៧៦ ករណី ឃាត់ខ្លួនមនុស្សបានជាង ៧ ៦០០នាក់ ក្នុងនោះស្រី ៥៤៥នាក់ និងចាប់បានគ្រឿងញៀនសរុបជាង ៣១២ គីឡូក្រាម[3]។ មនុស្សជាង ៧១១ នាក់ដែលភាគច្រើនជាយុវជនត្រូវបានចាប់ខ្លួននៅឯមជ្ឈមណ្ឌលកម្សាន្ត រ៉ក់ (Rock) និងលុចសារី (Luxury) នៅកណ្ដាលរាជធានីភ្នំពេញក្នុងឆ្នាំ ២០១៩ ជាមួយនឹងគ្រឿងញៀនជាង ៥០ គីឡូក្រាម។ មនុស្សប្រមាណ ៤០០ នាក់ក្នុងចំណោមពួកគេត្រូវបានរកឃើញថាមានផ្ទុកសារធាតុញៀន។

ការសិក្សារបស់របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (NACD) ក្នុងឆ្នាំ ២០១៥ បានបង្ហាញថា បញ្ហាគ្រឿងញៀនបានជះឥទ្ធិពលយ៉ាងខ្លាំងដល់ការសិក្សា និងការអភិវឌ្ឍកុមារ និងយុវជននៅកម្ពុជា។ អ្នកប្រើប្រាស់គ្រឿងញៀនប្រមាណជា ៨៧,៨៩ % ជាយុវជនមានអាយុចន្លោះពី ១៨ ទៅ ៣៥ ឆ្នាំ ដែល ៤៦.៣៣ % នៃពួកគេមិនមានជំនាញ និងការងារជាក់លាក់ ហើយ ១៨.៣% ជាសិស្សសាលា និងនិស្សិតរៀននៅសាកលវិទ្យាល័យ។ គ្រឿងញៀន គឺជាសារធាតុគីមី ឬរុក្ខជាតិ បង្ករឥទ្ធិពលខ្លាំងទៅលើផ្លូវចិត្ត និងផ្លូវកាយ ដែលធ្វើឱ្យអ្នកប្រើប្រាស់មានអារម្មណ៍រវើរវាយ អណ្តែតអណ្តូង ឬ ក្លាហានខុសពីលក្ខណៈធម្មតា ធ្វើអោយស្ពឹកស្រពន់ បាត់ការឈឺចុកចាប់ និងភាពអស់កម្លាំង បង្ករបញ្ហាអសន្តិសុខ ការប្រព្រឹត្តអំពើហិង្សា អំពើលួចប្លន់ អំពើមនុស្សឃាត បែកបាក់គ្រួសារ បាត់បង់សមត្ថភាពក្នុងការរៀនសូត្រ សមត្ថភាពក្នុងការបំពេញការងារ បាត់បង់អាជីព និងធ្វើឱ្យសីលធម៌សង្គមមានការធ្លាក់ចុះជាដើម។

ការសិក្សាបឋមអំពីសុវត្ថិភាព និងការព្រួយបារម្ភរបស់កុមារ និងយុវជនក្នុងសហគមន៍ ត្រូវបានធ្វើឡើងនៅដើមឆ្នាំ ២០១៩ ជាមួយប្រធាន និងតំណាងក្រុមកុមារ និងយុវជនស្ម័គ្រចិត្ត ក្នុងសហគមន៍ក្នុង ៧ ស្រុក-ខណ្ឌ និង ៥ រាជធានី-ខេត្ត រួមមានស្រុកអូរជ្រៅ និងសិរីសោភ័ណខេត្តបន្ទាយមានជ័យ ស្រុកថ្មគោល និងឯកភ្នំ ខេត្តបាត់ដំបង ស្រុកស្នួល ខេត្តក្រចេះ ស្រុកកោះញែកខេត្តមណ្ឌលគិរី និង ខណ្ឌដង្កោ រាជធានីភ្នំពេញ។ ពួកគេបានលើកឡើងថា បញ្ហាគ្រឿងញៀនជាបញ្ហាចម្បងជាងគេដែលបានកើតឡើងក្នុងសហគមន៍ ហើយវាបានជះឥទ្ធិពលយ៉ាងខ្លាំងដល់ការរៀនសូត្រ សន្តិសុខ និងអនាគតរបស់ពួកគេ។

---

[3] សារព័តមាន VOD «អាជ្ញាធរ ចាប់បានថ្នាំញៀន៣១២គីឡូក្រាមក្នុងរយៈពេល៦ខែនៃឆ្នាំ២០១៩» ចុះថ្ងៃទី ១៦ កក្កដា ២០១៩

ក្នុងនាមជាក្រុមកុមារ និងយុវជនស្ម័គ្រចិត្តក្នុងសហគមន៍ ពួកយើងមើលឃើញថា បញ្ហាគ្រឿងញៀន គឺជាបញ្ហាចំបងបំផុតដែលជះឥទ្ធិពលយ៉ាងខ្លាំងដល់សុវត្ថិភាព ការអប់រំ និងអនាគតរបស់យើងខ្ញុំផ្ទាល់ ក៏ដូចជាកុមារ និងយុវជនផ្សេងទៀតក្នុងសហគមន៍ ដែលទាមទារឱ្យមានការសិក្សាច្បាស់លាស់អំពីផលប៉ះពាល់ ដើម្បីស្វែងរកកិច្ចអន្តរាគមន៍ និងដោះស្រាយជាបន្ទាន់។ វាបានក្លាយជាការចាប់ផ្តើមដ៏ល្អមួយ បន្ទាប់ពីមានការគាំទ្រពីអង្គការហ្គូដណេប៊ឺកម្ពុជា (GNC) និងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (NACD) តាមរយៈការបណ្តុះបណ្តាល ការផ្តល់បច្ចេកទេស និងធនធានជាដើម។ យើងខ្ញុំសង្ឃឹមថា ការសិក្សាអំពីស្ថានភាពនៃការប្រើប្រាស់គ្រឿងញៀនក្នុងសហគមន៍នេះ នឹងក្លាយជាកិច្ចចាប់ផ្តើមដ៏ល្អមួយដើម្បីចូលរួមចំណែកក្នុងការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងគ្រឿងញៀនដើម្បីភាពប្រសើរឡើងនៃ សុវត្ថិភាព ការអប់រំ និងការអភិវឌ្ឍកុមារ និងយុវជន។

## ២. គោលបំណងនៃការស្ទង់មតិ

- សិក្សាអំពីការយល់ដឹង ផលប៉ះពាល់ និងសំណូមពររបស់កុមារអំពីបញ្ហាគ្រឿងញៀនកើតឡើងក្នុងសហគមន៍ដែលពួកគេរស់នៅ។
- ចងក្រងជាឯកសារដើម្បីចែករំលែក និងផ្តល់ជូនអាជ្ញាធរមូលដ្ឋាន មន្ត្រីរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធដើម្បីចូលរួមអន្តរាគមន៍ និងប្រយុទ្ធប្រឆាំងគ្រឿងញៀនកាន់តែមានប្រសិទ្ធិភាពទាំងក្នុងសាលារៀន និងសហគមន៍។

## ៣. វិធីសាស្ត្រនៃការស្ទង់មតិ

### ៣.១ ទម្រង់នៃការស្ទង់មតិ និងការកំណត់សំណាក

ការសិក្សានេះត្រូវបានធ្វើឡើងក្នុងទម្រង់ជាបរិមាណវិស័យដោយការកំណត់យក ២៨៣ សំណាកស្ថិតក្នុង ៨១ភូមិ ១៩ ឃុំ-សង្កាត់ ៧ស្រុក-ខណ្ឌ នៃរាជធានីភ្នំពេញ ខេត្តបន្ទាយមានជ័យ បាត់ដំបង ក្រចេះ និងមណ្ឌលគិរី ដែលជាទីតាំងអនុវត្តកម្មវិធីរបស់អង្គការហ្គូដណេប៊ឺសកម្ពុជា និងក៏ជាទីតាំងដែលក្រុមកុមារ និងយុវជនស្ម័គ្រចិត្តរស់នៅ។ កុមារទាំងក្នុង និងក្រៅសាលាដែលមានអាយុចន្លោះពី ១៣ ទៅ ១៨ ឆ្នាំគឺជាក្រុមគោលដៅសម្រាប់កិច្ចសម្ភាសន៍ដែលពួកគេត្រូវបានជ្រើសតាមទម្រង់គំរូតាមគោលបំណង (Purposive Sampling) និងធានាអំពីសមភាពរវាងកុមារា និងកុមារី។ ការចុះប្រមូលទិន្នន័យត្រូវបានធ្វើឡើងចាប់ពីថ្ងៃទី ១៣ ខែឧសភា ដល់ថ្ងៃទី ៦ ខែកក្កដា ឆ្នាំ២០១៩។

## ៣.២ កម្រងសំណួរ និងការចុះប្រមូលទិន្នន័យ

កម្រងសំណួរត្រូវកំណត់ និងសម្រេចដោយតំណាងក្រុមយុវជនបន្ទាប់ពីការពង្រៀងដោយបុគ្គលិកបច្ចេកទេសអង្គការហ្វូដណេបឺសកម្ពុជា ក្នុងពេលរៀបចំសិក្ខាសាលាស្តីពីការចូលរួមរបស់កុមារ និងយុវជនក្នុងការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលបានរៀបចំឡើងដោយអង្គការហ្វូដណេបឺសកម្ពុជា នៅរាជធានីភ្នំពេញ កាលពីដើមខែឧសភា ឆ្នាំ២០១៩ និងបានពិនិត្យដោយមន្ត្រីបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (NACD)។ បន្ទាប់ពីការធ្វើតេស្តកម្រងសំណួរ តំណាងក្រុមយុវជន ស្ម័គ្រចិត្តដែលទទួលបានការបណ្តុះបណ្តាល បានចុះប្រមូលទិន្នន័យនៅក្នុងសាលារៀន និងសហគមន៍ដែលពួកគេរស់នៅ ហើយការជ្រើសទីតាំង និងតំបន់ផ្សេងៗ គឺត្រូវធានាអំពីសុវត្ថិភាពផ្ទាល់ខ្លួនជាចំបង។ ការប្រមូលទិន្នន័យក្នុងសាលារៀន បានធ្វើឡើងដោយមានការអនុញ្ញាតពីនាយកសាលា គ្រូបង្រៀន និងយល់ព្រមពីកុមារផ្ទាល់ ខណៈការប្រមូលទិន្នន័យក្នុងសហគមន៍ត្រូវមានការអនុញ្ញាតពីអាជ្ញាធរមូលដ្ឋាន អាណាព្យាបាល និងកុមារផ្ទាល់ ដែលការយល់ព្រមនេះធ្វើឡើងដោយប្រើទម្រង់ការយល់ព្រមរបស់កុមារ (ដូចមានក្នុងឯកសារភ្ជាប់ ២)។ ក្រុមចុះប្រមូលទិន្នន័យ បានបែងចែកជាប្រធានក្រុម និងសមាជិកដើម្បីងាយស្រួលក្នុងការចុះសម្ភាសន៍ ពិនិត្យមើលលទ្ធផលនៃការសម្ភាសន៍ និងស្វែករកការគាំទ្រពីបុគ្គលិក អង្គការហ្វូដណេបឺសកម្ពុជា ប្រចាំកម្មវិធីអភិវឌ្ឍន៍សហគមន៍ នីមួយៗ។

## ៣.៣ ការបញ្ចូលទិនន្នន័យ ការវិភាគ និងការសរសេររបាយការណ៍

ការបញ្ចូលទិន្នន័យត្រូវបានធ្វើឡើងដោយយុវជនស្ម័គ្រចិត្តផ្ទាល់តាមប្រព័ន្ធអេឡិចត្រូនិច (Google Form) ដែលបង្កើតឡើងដោយបុគ្គលិកបច្ចេកទេសរបស់អង្គការហ្វូដណេបឺសកម្ពុជា។ លទ្ធផលនៃការបញ្ចូលនិន្នន័យនេះត្រូវបានវិភាគនេះដោយស្វ័យប្រវត្តិ ខណៈដែលការត្រួតពិនិត្យ និងការបញ្ជាក់បន្ថែមលើគុណភាពត្រូវបានធ្វើឡើងក្នុងពេលដំណាលគ្នា។

ការសរសេររបាយការណ៍ ត្រូវបានធ្វើឡើងដោយតំណាងក្រុមយុវជនស្ម័គ្រចិត្តនៅតំបន់គោលដៅនីមួយៗ ដោយបែងចែកតាមផ្នែកដោយយោងទៅលើទម្រង់សរសេររបាយការណ៍ដែលមានស្រេច។ បន្ទាប់ពីតំណាងក្រុមនីមួយៗសរសេរ និងបញ្ចប់តាមផ្នែកដែលទទួលខុសត្រូវ ពួកគេបញ្ជូនលទ្ធផលនេះទៅបុគ្គលិកបច្ចេកទេសអង្គការហ្វូដណេបឺសកម្ពុជាប្រចាំកម្មវិធីអភិវឌ្ឍន៍សហគមន៍នីមួយៗដើម្បីត្រួតពិនិត្យគុណភាព មុនពេលផ្ញើរមកកាន់ក្រុមយុវជនស្ម័គ្រចិត្តនៅខណ្ឌដង្កោរក្នុងរាជធានីភ្នំពេញ ដើម្បីដាក់បញ្ចូលក្នុងរបាយការណ៍រួម។

### ៣.៤ ការត្រួតពិនិត្យបច្ចេកទេស និងគុណភាព

ក្រុមផ្តល់បច្ចេកទេស និងត្រួតពិនិត្យត្រូវបានបង្កើតឡើងក្នុងចំណោមបុគ្គលិកអង្គការហ្វូដណេប៊ីសកម្ពុជា ទាំងនៅរាជធានីភ្នំពេញ និងនៅកម្មវិធីអភិវឌ្ឍន៍សហគមន៍តាមបណ្តាខេត្តនានា។ ក្រុមនេះ បង្កើតឡើងក្នុងគោលបំណងជួយបណ្តុះបណ្តាល ផ្តល់បច្ចេកទេស និងសម្របសម្រួលដល់ក្រុមយុវជនស្ម័គ្រចិត្តដើម្បីអោយពួកមានសមត្ថភាព និងអាចសម្រេចចិត្តលើកម្រងសំណួរ ការចុះប្រមូលទន្នន័យ និងសរសេររបាយការណ៍បាន។ ជាលទ្ធផល ក្រុមផ្តល់បច្ចេកទេស និងត្រួតពិនិត្យជាអ្នកពង្រៀងកម្រងសំណួរ បង្កើតទម្រង់បញ្ចូលទិន្នន័យ (Google Form) និងទម្រង់សរសេររបាយការណ៍ ផ្តល់បច្ចេកទេសពេលយុវជនចុះប្រមូលទិន្នន័យ ពិនិត្យ និងជួយសម្រួលលើរបាយការណ៍ដែលសរសេរដោយក្រុមយុវជន មុនពេលដាក់ជូនក្រុមប្រឹក្សាយោបល់ដើម្បីពិនិត្យខ្លឹមសារ និងគុណភាព។

# ៤. វិសាលភាព និងដែនកំណត់

ការសិក្សានេះឆ្លុះបញ្ចាំង និងមានវិសាលភាពគ្របដណ្តប់លើតំបន់គោលដៅដែលបានចុះប្រមូលទិន្នន័យ គឺស្ថិតក្នុង ៨១ភូមិ ១៩ ឃុំ-សង្កាត់ និង៧ ស្រុក-ខណ្ឌ នៃរាជធានីភ្នំពេញ ខេត្តបន្ទាយមានជ័យ បាត់ដំបង ក្រចេះ និងមណ្ឌលគិរី។ នេះគឺជាការដកស្រង់ និងបង្ហាញនូវបទពិសោធន៍ជាក់ស្តែងដែលកុមារបានឃើញ ជួបប្រទះ និងការព្រួយបារម្ភរបស់គេផ្ទាល់ជុំវិញបញ្ហាគ្រឿងញៀនក្នុងសហគមន៍ដែលពួកគេរស់នៅ។ ដូច្នេះ លទ្ធផលនៃការសិក្សានេះ មានសុពលភាព និងសុក្រឹត្យភាពគ្រប់គ្រាន់សម្រាប់ការប្រើប្រាស់។ យ៉ាងណាក្តី ការសិក្សានេះ មិនឆ្លុះបញ្ចាំង ឬ តំណាងអោយថ្នាក់ជាតិទាំងមូលនោះទេ។

# ៥. លទ្ធផលនៃការស្ទង់មតិ

## ៥.១ ព័ត៌មានទូទៅ

ការស្ទង់មតិនេះ បានធ្វើឡើងក្នុងចំណោមកុមារចំនួន ២៨៣នាក់ (ស្រី១៦៦នាក់) ដែលពួកគេមានអាយុចន្លោះពី ១៣ ដល់ ១៨ឆ្នាំ ស្ថិតក្នុង ១៩ ឃុំ និង ៧ ស្រុក-ខណ្ឌនៃខេត្តបន្ទាយមានជ័យ បាត់ដំបង ក្រចេះ មណ្ឌលគិរី និងរាជធានីភ្នំពេញ។ កុមារដែលចូលរួមក្នុងកិច្ចសម្ភាសន៍ភាគច្រើនមកពីស្រុកអូជ្រៅ និងស្រុកសិរីសោភ័ណខេត្តបន្ទាយមានជ័យមានចំនួន ៣៨.៨០% ស្រុកថ្មគោល និងស្រុកឯកភ្នំខេត្តបាត់ដំបងមានចំនួន ២៥.៨០% ស្រុកស្នួលខេត្តក្រចេះមានចំនួន ១៣.៨០ % ស្រុកកោះញែក ខេត្តមណ្ឌលគិរីមានចំនួន ១៣.៨០% និងខណ្ឌដង្កោ រាជធានីភ្នំពេញមានចំនួន ១៧.៧ %។




*រូបភាពទី 1: សំណាកកុមារចូលរួមសម្ភាសន៍នៅតាមតំបន់នីមួយៗ*

ក្នុងចំណោមកុមារឆ្លើយសំណួរទាំងអស់ មាន ១៩.១% ឬ ៥៤នាក់ ជាកុមារក្រៅសាលា ដែលពួកគេភាគច្រើនឈប់រៀននៅថ្នាក់ទី ៥ និងថ្នាក់ទី ៧ មានប្រមាណ ២៥.៥ និង ២៩.៤ %។ កុមារក្នុងសាលា ភាគច្រើនរៀននៅថ្នាក់វិទ្យាល័យ ដែលថ្នាក់ទី ១០ មាន ១៩% ថ្នាក់ទី ១១ មាន ១៧.៣% និងថ្នាក់ទី ១២ មានចំនួន ១៣.៤ %។ ក្រៅពីនេះ ពួកគេរៀននៅកម្រិតអនុវិទ្យាល័យ និងបឋមសិក្សា។

## ៥.២. ការយល់ដឹងពីគ្រឿងញៀន

កុមារចំនួន ៩២.២% ឬ ស្មើនឹង ២៦១ នាក់ ដែលបានចូលរួមឆ្លើយសំណួរបានរាយការណ៍ថា ពួកគាត់ធ្លាប់លឺព័ត៌មានអំពីបញ្ហាគ្រឿងញៀន។ ប្រភពព័ត៌មានសំខាន់ៗដែលពួកគេទទួលបាន គឺតាមរយៈ ទូរទស្សន៍មានចំននួន ៦៨.៤ % បណ្តាញសង្គមហ្វេសប៊ុក (Facebook) មានចំនួន ៦២ % និងគ្រូបង្រៀនមានចំនួន ៤៩%។




*រូបភាពទី 2: ប្រភពព័ត៌មានសំខាន់ៗដែលផ្សព្វផ្សាយអំពីគ្រឿងញៀន*

ការចរាចរ និងការប្រើប្រាស់គ្រឿងញៀន ពិតជាមានផលប៉ះពាល់ដល់កុមារ យុវជន និងសហគមន៍ទាំងមូល។ កុមារចំនួន ៩៥.៧% នៃអ្នកដែលបានចូលរួមឆ្លើយសំណួរបាននិយថា គ្រឿងញៀនបង្កឱ្យមានអំពើលួចប្លន់មានចំនួន ៦៤ % អំពើហឹង្សាក្នុងគ្រួសារចំនួន ៤៦.៦% អំពើហឹង្សាលើអ្នកដ៏ទៃ ៥០.៤០ % ក្មេងទំនើងមានចំនួន ៤៨.៩% បញ្ហាអសន្តិសុខសង្គមមាន ៤២ % និងបញ្ហាផ្សេងទៀតមានបែកបាក់គ្រួសារ ការធ្វើអត្តឃាត និងប្រព្រឹត្តអំពើពេស្យាចារជាដើម




រូបភាពទី 3: ផលប៉ះពាល់នៃគ្រឿងញៀន

## ៥.៣: ការអង្កេតអំពីការប្រើប្រាស់គ្រឿងញៀនក្នុងរយៈពេល ១២ ខែចុងក្រោយ

ការសិក្សាបានបង្ហាញថា កុមារចំនួន ៨៤.១% ធ្លាប់ឃើញការជួញដូរគ្រឿងញៀនក្នុងសហគមន៍ដែលពួកគេរស់នៅ។ ទោះយ៉ាងនេះក្តី កុមារភាគច្រើនមិនហ៊ានរាយការណ៍ ឬ ធ្វើអ្វីទាំងអស់ ដែលទិន្នន័យនេះមានប្រមាណ ៤៧%។ មានភាគរយតិចណាស់ដែលកុមារហ៊ានរាយការណ៍ទៅកាន់ឪពុកម្តាយ និងអាជ្ញាធរ។




*រូបភាពទី 4: កុមារធ្លាប់ឃើញការប្រើប្រាស់គ្រឿងញៀនក្នុងសហគមន៍*

ដូចមានបង្ហាញក្នុងរូបភាពទី ៤ កុមារប្រមាណ ៨១.១ % រាយការណ៍ថា ពួកគេធ្លាប់ឃើញគេប្រើប្រាស់គ្រឿងញៀន ដែលក្នុងនោះ មាន ៧០.២%បញ្ជាក់ថា ធ្លាប់ឃើញគេប្រើគ្រឿងញៀនក្នុងសហគមន៍ដែលពួកគេរស់នៅ ។ បើតាមការបញ្ជាក់ កុមារ ៧៥% បង្ហាញថា អ្នកដែលប្រើប្រាស់គ្រឿងញៀនភាគច្រើនជាមនុស្សមានអាយុចន្លោះពី ១៨ ទៅ ៣០ ឆ្នាំ និងកុមារចំនួន ២៦.៥ %រាយការណ៍ថា ធ្លាប់បានឃើញកុមារដែលមានអាយុក្រោម ១៨ ឆ្នាំប្រើប្រាស់គ្រឿងញៀនផងដែរ។ តាមការអង្កេតរបស់កុមារផ្ទាល់ អ្នកប្រើប្រាស់គ្រឿងញៀនទាំងនោះមានសភាពស្គមស្គាំង ភ័យក្លាច រវើរវាយ ឆេវឆាវ បាត់បងម្ចាស់ការលើខ្លួនឯង និងបង្កហឹង្សាលើអ្នកដ៏ទៃជាដើម។




*រូបភាពទី 5: ក្រុមអាយុអ្នកប្រើប្រាស់គ្រឿងញៀនក្នុងសហគមន៍*

កុមារភាគច្រើនមិនបានដឹងថាគ្រឿងញៀនដែលប្រើទាំងនោះ មានប្រភពមកពីណានោះទេ ប៉ុន្តែអ្នកដែលបានដឹងប្រមាណជា ១៥.៤០% បង្ហាញថា ភាគច្រើនជនពីខាងក្រៅជាអ្នកនាំចូលគ្រឿងញៀន ដែលក្នុងនោះក៏មានមិត្តភក្តិ និងអ្នកជិតខាងរបស់គាត់ដែរ។ មានកុមារតែម្នាក់គត់រាយការណ៍ថា អាជ្ញាធរមូលដ្ឋានជាប់ពាក់ព័ន្ធនឹងការនាំចូលនូវគ្រឿងញៀន។

## ៥.៤. សុវត្ថិភាពកុមារ

ដោយផ្អែកទៅលើស្ថានភាពសុវត្ថិភាពនៅក្នុងសហគមន៍ កុមារចំនួន ៧២.៤% រាយការណ៍ថាពួកគេភ័យខ្លាចមានគេណែនាំ លួងលោម ឬបង្ខំអោយប្រើប្រាស់គ្រឿងញៀន។ ដោយសារមានអ្នកប្រើប្រាស់គ្រឿងក្នុងសហគមន៍ កុមារចំនួន ៨៩.៧% ភ័យខ្លាចអ្នកប្រើប្រាស់គ្រឿងញៀនប្រព្រឹត្តអំពើអ្វីមួយមកលើពួកគេ រួមមាន ៧៣.៨% ខ្លាចការប្រើហឹង្សា ៥៣ % ខ្លាចមានអំពើលួចប្លន់ ៤៤.១% ខ្លាចមានការធ្វើឃាត និង ៣៩% ប្រព្រឹត្តពេស្យាចារមកលើពួកគេជាដើម។




*រូបភាពទី 6:កុមាររងផលប៉ះពាល់ដោយសារចរាចរ និងការប្រើគ្រឿងញៀនក្នុងសហគមន៍*

ដូចមានបង្ហាញក្នុងរូបភាពទី ៦ កុមារដែលបានចូលរួមឆ្លើយសំណួរបញ្ជាក់ថា ពួកគេពិតជាបានរងផលប៉ះពាល់ដោយសារតែចរាចរ និងមានគេប្រើប្រាស់គ្រឿងញៀនក្នុងសហគមន៍ដែលពួកគេរស់នៅ។ កុមារ ៤៤.៨០% និយាយថា ពួកគេមិនហ៊ាននៅផ្ទះតែម្នាក់ឯង ៤២.៥% មិនហ៊ានទៅសាលារៀន ៤១.៨% មិនហ៊ានធ្វើដំណើរទៅទីកន្លែងផ្សេងៗជាដើម។

កុមារចំនួន ៤.៩ % ឬ ១៤ នាក់ក្នុងចំណោមអ្នកដែលបានចូលរួមក្នុងកិច្ចសម្ភាសន៍បង្ហាញថា ពួកគេធ្លាប់ត្រូវបានគេណែនាំ និងលួងលោមឱ្យប្រើប្រាស់គ្រឿងញៀន ហើយអ្នកដែលណែនាំនោះ ភាគច្រើនជាមិត្តភក្តិ និងអ្នកជិតខាងរបស់ពួកគេ។




*រូបភាពទី 7: កុមារធ្លាប់ត្រូវគេណែនាំ លួងលោម ឬ បង្ខំឱ្យប្រើប្រាស់គ្រឿងញៀន*

កុមារ ៩នាក់ ឬ ៣.៤ % រាយការណ៍ថា ពួកគេធ្លាប់ប្រើប្រាស់គ្រឿងញៀន ហើយគ្រឿងញៀនទាំងនោះជាប្រភេទម៉ាទឹកកក ដែលពួកគេទទួលបានពីមិត្តភក្តិ និងអ្នកជិតខាង។

## ៥.៥. កិច្ចអន្តរាគមន៍

កុមារភាគច្រើនរៀបរាប់ថា ធ្លាប់ឃើញអាជ្ញាធរមូលដ្ឋាន (មេភូមិ ឃុំ/សង្កាត់ ប៉ូលីស) ចុះអប់រំ និងផ្សព្វផ្សាយអំពីផលប៉ះពាល់ និងការបង្ការខ្លួនពីការប្រើប្រាស់គ្រឿងញៀននៅក្នុងសហគមន៍ដែលពួកគេរស់នៅ ដែលទិន្នន័យមានប្រមាណ ៨៤.៦% ដោយឡែកកុមារចំនួន ១៥.៤% ផ្សេងទៀតមិនធ្លាប់ឃើញការផ្សព្វផ្សាយនេះទេ។ កុមារពន្យល់ថា ការផ្សព្វផ្សាយធ្វើឡើងតាមរយៈការចុះបង្រៀនតាមភូមិ បិទផ្សាយផ្ទាំងក្រដាស ផ្ទាំងប៉ាណូ ផ្សព្វផ្សាយក្នុងសាលារៀន និងបញ្ជ្រាបក្នុងកម្មវិធីអប់រំផ្សេងៗជាដើម។




បើតាមការបញ្ជាក់របស់កុមារ មន្ត្រីប៉ូលីសប៉ុស្តិ៍ចុះផ្សព្វផ្សាយច្រើនជាងគេ ដែលចំនួននេះមានរហូតដល់ ៨២.២០ % ការអប់រំដោយប្រធានភូមិមាន ៥៧.២% និងបន្ទាប់មកទៀតមានមន្ត្រីនៅឃុំ-សង្កាត់ និងក្រុមកុមារ និងយុវជនស្ម័គ្រចិត្តក្នុងសហគមន៍។

កុមារ ៤៦.៨% បង្ហាញថាពួកគេធ្លាប់ឃើញអាជ្ញាធរមូលដ្ឋានចុះបង្ក្រាប និងចាប់ខ្លួនអ្នកចែកចាយ ឬ ប្រើប្រាស់គ្រឿងញៀន ខណៈដែល ៥៣.២% ផ្សេងទៀតបញ្ជាក់ថាពួកគេមិនបានដឹង ឬ ឃើញអំពីការចុះបង្ក្រាប ឬ ចាប់ខ្លួនអ្នកចែកចាយ ឬ ប្រើប្រាស់គ្រឿងញៀនរបស់អាជ្ញាធរនោះទេ។ កុមារដែលបានដឹង ឬ ឃើញសកម្មភាពនេះបានពន្យល់អំពីនិតិវិធីផ្សេងៗដែលអាជ្ញាធរបានធ្វើ ក្នុងនោះរួមមាន ៤៩% ធ្លាប់ដឹងថាអាជ្ញាធរបានធ្វើការអប់រំមុននឹងដោះលែង ៤៥.៤០% ធ្លាប់ដឹងថាអាជ្ញាធរបញ្ជូនទៅពន្ធធនាគារ និងក្រៅពីនេះមានបញ្ជូនទៅតុលាការ និងផាកពិន័យជាលុយកាក់។

## ៦. សេចក្តីសន្និដ្ឋាន

ការកើនឡើងនៃចរាចរ និងការប្រើប្រាស់គ្រឿងញៀនបានក្លាយជាបញ្ហាប្រឈមដ៏ធំមួយរាំងស្ទះដល់ការអភិវឌ្ឍន៍សង្គមកម្ពុជាស្ទើរគ្រប់ផ្នែក។ បញ្ហាគ្រឿងញៀនបានរីករាយដាលទាំងនៅរាជធានីភ្នំពេញ តាមបណ្តាខេត្ត និងក្នុងសហគមន៍ដាច់ស្រយ៉ាល ហើយបានបង្កភាពភ័យខ្លាច និងផលប៉ះពាល់យ៉ាងខ្លាំងដល់សុវត្ថិភាព ជីវភាព សុខភាព សុខមាលភាព និងការអប់រំរបស់ប្រជាជន ពិសេសកុមារ និងយុវជនទាំងនៅទីប្រជុំជន និងតំបន់ដាច់ស្រយ៉ាល។

កុមារភាគច្រើនបានរាយការណ៍អំពីបទពិសោធន៍ដែលពួកគេជួបប្រទះនូវទិដ្ឋភាពនៃការជួញដូរ និងប្រើប្រាស់គ្រឿងញៀនក្នុងសហគមន៍ ព្រមទាំងផលប៉ះពាល់របស់វាលើអ្នកប្រើប្រាស់ ក្រុមគ្រួសារ និងអ្នកនៅជុំវិញខ្លួន។ អ្នកប្រើប្រាស់គ្រឿងញៀន ត្រូវបានរាយការណ៍ថា មានសភាពស្គមស្គាំង ភ័យខ្លាច រវើរវាយ ឆេវឆាវ បាត់បង់ម្ចាស់ការលើខ្លួនឯង បង្កហឹង្សាក្នុងគ្រួសារ និងលើអ្នកដ៏ទៃ បែកបាក់គ្រួសារ និងបង្កសកម្មភាពលួចប្លន់។ សម្រាប់កុមារផ្ទាល់ ពួកគេពិតជាមានការភ័យខ្លាច ទោះអំឡុងពេលនៅផ្ទះម្នាក់ឯង ការធ្វើដំណើរ ការទៅសាលារៀន និងចូលរួមសកម្មភាពផ្សេងៗក្នុងសហគមន៍។ វាជាការព្រួយបារម្ភបំផុត នៅពេលដែលកុមារជាច្រើននាក់ចែករំលែកថា ពួកគេធ្លាប់ត្រូវបានណែនាំ និងលួងលោមឱ្យប្រើប្រាស់គ្រឿងញៀន និងអ្នកខ្លះទៀតបានប្រើប្រាស់គ្រឿងញៀនរួចទៅហើយ។ នេះបង្ហាញថា គ្រឿងញៀនបានបង្កផលប៉ះពាល់ដល់សុវត្ថិភាព សុខភាព ការអប់រំ និងការអភិវឌ្ឍកុមារ និងយុវជនកម្ពុជា ដែលតម្រូវឱ្យមានកិច្ចអន្តរាគមន៍ និងទប់ស្កាត់ជាបន្ទាន់ពីសំណាក់អាជ្ញាធរមូលដ្ឋាន រដ្ឋាភិបាល និងអ្នកពាក់ព័ន្ធ ដើម្បីជាប្រយោជន៍សម្រាប់កុមារ ប្រជាជន និងសង្គមជាតិទាំងមូល។

## ៧. សំណូមពរ

លទ្ធផលនៃការស្ទង់មតិបានបង្ហាញឱ្យឃើញថា កុមារ យុវជន និងប្រជាជនកម្ពុជាកំពុងរងផលប៉ះពាល់ពីការចរាចរ និងការកើនឡើងនៃគ្រឿងញៀន ដែលនេះបានក្លាយជាបញ្ហាប្រឈមយ៉ាងធ្ងន់ធ្ងរ និងរាំងស្ទះដល់ការអភិវឌ្ឍសង្គមទាំងមូល។ ដើម្បីធានាថា បញ្ហាគ្រឿងញៀនត្រូវបានទប់ស្កាត់ ហើយទាំងកុមារ និងយុវជន ក៏ដូចជាសហគមន៍ទាំងមូលមានសុវត្ថិភាព យើងខ្ញុំជាយុវជនស្ម័គ្រចិត្តសូមធ្វើការសំណូមពរដូចខាងក្រោម៖

- ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាព

- បង្កើនកម្មវិធីអប់រំ ផ្សព្វផ្សាយ និងចុះអនុវត្តជាក់ស្តែងអោយបានទៀងទាត់ពីសំណាក់អាជ្ញាធរ គ្រូបង្រៀន និងអ្នកពាក់ព័ន្ធអំពីផលប៉ះពាល់នៃគ្រឿងញៀន និងរបៀបបង្ការខ្លួនដល់កុមារ យុវជន និងសហគមន៍ទាំងមូល
- ពង្រឹងការអនុវត្តច្បាប់ឱ្យបានតឹងរឹងទៅលើអ្នកផលិត និងជួញដូរគ្រឿងញៀន
- បង្កើតបណ្តាញទំនាក់ទំនង និងស៊ើបអង្កេតដែលមានតម្លាភាព និងប្រសិទ្ធភាពដើម្បីស្វែងរក និងទប់ស្កាត់សេពគ្រឿងញៀនក្នុងសាលារៀន និងសហគមន៍ដើម្បីអប់រំ និងអន្តរាគមន៍ទាន់ពេល
- ពង្រឹងការត្រួតពិនិត្យសារធាតុញៀនក្នុងចំណោមសិស្ស និស្សិត និងអាជ្ញាធរខ្លួនឯងផ្ទាល់ឱ្យមានប្រសិទ្ធភាព និងតម្លាភាព
- លើកទឹកចិត្តដល់យុវជន និងប្រជាជនក្នុងសហគមន៍ចូលរួមរាយការណ៍អំពីបញ្ហាគ្រឿងញៀនដល់សមត្ថកិច្ច ឬជនបង្គោលដើម្បីអន្តរាគមន៍ទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព។

# ៨. ឯកសារភ្ជាប់

## ឯកសារភ្ជាប់ទី ១៖ កម្រងសំណួរ

## កម្រងសំណួរអំពីស្ថានភាពនៃការប្រើប្រាស់ថ្នាំញៀននៅក្នុងសហគមន៍

សួស្តី ខ្ញុំឈ្មោះ…………………។ ខ្ញុំជាកុមារ / យុវជនស្ម័គ្រចិត្តអង្គការហ្វូដណោបឹសកម្ពុជា កំពុងធ្វើការសិក្សាអំពីការយល់ដឹង និងស្ថានភាពនៃការប្រើប្រាស់គ្រឿងញៀនក្នុងសហគមន៍។ ព័ត៌មាននានាដែលអ្នកផ្តល់ឱ្យតាមរយៈការសម្ភាសន៍នេះ គឺពិតជាមានសារៈសំខាន់ណាស់ ដើម្បីបានជាមូលដ្ឋានគ្រឹះក្នុងការរៀបចំផែនការជាក់លាក់លើកកម្ពស់ការយល់ដឹងដល់កុមារ យុវជន អាណាព្យាបាល និងអ្នកពាក់ព័ន្ធអំពីផលប៉ះពាល់នៃគ្រឿងញៀន ចូលរួមទប់ស្កាត់ និងលុបបំបាត់ការប្រើប្រាស់គ្រឿងញៀនក្នុងសគមន៍មានប្រសិទ្ធភាព។ ឈ្មោះ និងពត៌មានផ្សេងៗដែលអ្នកផ្តល់អោយ នឹងរក្សាទុកជាការសម្ងាត់ ហើយបទសម្ភាស៍នេះ នឹងត្រូវការពេលវេលាប្រហែល ១៥នាទី។ តើអ្នកអាចចូលរួមបានឬ ទេ?

**សូមគូសចម្លើយ៖** ☐បាទ/ចាស ☐ទេ

**កំណត់សម្គាល់៖** *ប្រសិនបើឆ្លើយថាទេ ចូរនិយាយអរគុណទៅកាន់គាត់ ហើយបន្តសួរទៅកាន់អ្នកផ្សេងទៀត*

| Code: ……………… | ឈ្មោះអ្នកសម្ភាសន៍:……………………....លេខទូរស័ព្ទ…………...……….កាលបរិច្ឆេទ………/……/2019 |
|---|---|

ឈ្មោះអ្នកត្រូវសម្ភាសន៍………..……………………………ភេទ:……..……អាយុ:……………ឆ្នាំ នៅភូមិ………………………….... ឃុំ/សង្កាត់……………………..ស្រុក/ខណ្ឌ…………..………………......ខេត្ត/រាជធានី………..……………………………………

ស្ថានភាពសិក្សា: ☐ រៀន (ថ្នាក់ទី……………….)

☐ ឈប់រៀន (ថ្នាក់ទី ………….....ឈប់រយៈពេល……………..…….ឆ្នាំ

ស្ថានភាពគ្រួសារ: ☐ ក្រីក្រ ☐ មធ្យម ☐ ធូរធារ ចំនួនសមាជិកក្នុងគ្រួសារ…….នាក់ បងប្អូនបង្កើត…នាក់ (……នៅរៀន)

## ផ្នែកទី ១៖ ការយល់ដឹងពីគ្រឿងញៀន

| ល.រ | សំណួរ | ចម្លើយ |
|---|---|---|
| S1Q1 | តើអ្នកធ្លាប់លឺព័ត៌មាន ឬ លឺគេនិយាយអំពីគ្រឿងញៀនដែរ ឬទេ? | ☐ បាទ/ ចាស ☐ អត់ទេ (រំលងទៅ S1Q3) |
| S1Q2 | បើបាទ ឬ ចាស តើអ្នកលឺតាមរយៈប្រភពអ្វីខ្លះ? | ☐ ទូរទស្សន៍<br>☐ វិទ្យុ<br>☐ បណ្តាញសង្គម Facebook<br>☐ កាសែត<br>☐ ទស្សនាវដ្តី<br>☐ គ្រូបង្រៀន |

| | | |
|---|---|---|
| | | ☐ ឪពុកម្ដាយ អាណាព្យាបាល<br>☐ មនុស្សចាស់ក្នុងភូមិ<br>☐ យុវជនក្នុងសហគមន៍<br>☐ កុមារក្នុងសហគមន៍<br>☐ អាជ្ញាធរ (ប៉ូលីស មេភូមិ ឃុំ…)<br>☐ ផ្សេងៗ……………………………………………… |
| S1Q3 | តើការប្រើប្រាស់គ្រឿងញៀន មានផលប៉ះពាល់ដល់កុមារ យុវជន ក្រុមគ្រួសារ និងសហគមន៍ ឬទេ? | ☐ បាទ / ចាស ☐ អត់ទេ (រំលងទៅ S2Q1) |
| S1Q4 | បើបាទ ឬ ចាស តើប៉ះពាល់អ្វីខ្លះ? | ☐ អំពើលួចប្លន់<br>☐ អំពើហឹង្សាលើអ្នកដទៃ (វាយ សម្លុត គម្រាម)<br>☐ អត្តឃាត (សម្លាប់ខ្លួន)<br>☐ អំពើលួចប្លន់<br>☐ ក្មេងទំនើង<br>☐ ប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ<br>☐ បែកបាក់គ្រួសារ<br>☐ ប្រព្រឹត្តពេស្យាចារ (រំលោភ)<br>☐ លួងលោម ឬ បង្ខំឱ្យគេប្រើថ្នាំញៀន<br>☐ អសន្តិសុខក្នុងសង្គម<br>☐ ផ្សេ<br>ងៗ…………………………………………………. |
| **ផ្នែកទី ២៖ ការអង្កេតអំពីការប្រើប្រាស់គ្រឿងញៀនក្នុងរយៈពេល ១២ ខែចុងក្រោយ** | | |
| S2Q1 | តើអ្នកធ្លាប់ឃើញគេជួញដូរគ្រឿងញៀននៅក្នុងសហគមន៍របស់អ្នកដែរ ឬ ទេ? | ☐ បាទ ចាស ☐ អត់ទេ (រំលងទៅ S2Q3) |
| S2Q2 | ប្រើសិនបើបាទ ឬ ចាស តើអ្នកបានធ្វើដូចម្ដេច? | ☐ មិនធ្វើអ្វីទាំងអស់<br>☐ ចែករំលែកព័ត៌មានទៅគ្រួសារ (ឪពុកម្ដាយ បងប្អូន ….)<br>☐ រាយការណ៍ទៅអាជ្ញាធរមូលដ្ឋាន(មេភូមិ ឃុំ ប៉ូលីស ប្រជាការពារ)<br>☐ រាយការទៅគ្រូបង្រៀន នាយកសាលារ គណៈកម្មការទ្រទ្រង់សាលា<br>☐ ផ្សព្វផ្សាយតាមបណ្ដាញសង្គម (ហ្វេសប៊ុក)<br>☐ ផ្សេងៗ…………………………………………… |
| S2Q3 | តើអ្នកធ្លាប់ឃើញគេប្រើប្រាស់គ្រឿងញៀនដែរឬទេ? | ☐ បាទ ចាស ☐ អត់ទេ (រំលងទៅ S3Q1) |
| S2Q4 | បើបាទឬ ចាស តើអ្នកធ្លាប់ឃើញនៅកន្លែងណាខ្លះ? | ☐ ខេត្ត ឬ ក្រុងផ្សេង (រំលងទៅ S3Q1) |

| | | |
|---|---|---|
| | | ☐ ក្នុងខេត្តដែលអ្នករស់នៅ (ស្រុកផ្សេង) (រំលងទៅ S3Q1)<br>☐ ក្នុងសហគមន៍ដែលអ្នករស់នៅ (ភូមិ ឃុំ ស្រុក-ខណ្ឌ)<br>☐ ផ្សេងៗ………………………………………… |
| S2Q5 | បើមាននៅក្នុងសហគមន៍ តើជាមនុស្សវ័យណាខ្លះ? | ☐ កុមារ (អាយុក្រោម ១៨ ឆ្នាំ)<br>☐ យុវជន (១៨ - ៣០ ឆ្នាំ)<br>☐ មនុស្សវ័យកណ្តាល<br>☐ មនុស្សចាស់<br>☐ ផ្សេងៗ………………………………………. |
| S2Q6 | តើអ្នកធ្លាប់ស្គាល់អ្នកដែលប្រើប្រាស់គ្រឿងញៀននោះឬទេ? | ☐ បាទ ចាស ☐ អត់ទេ (រំលងទៅ S2Q8) |
| S2Q7 | បើបាទ ឬ ចាស តើគាត់មានស្ថានភាពដូចម្តេចបន្ទាប់ពីប្រើគ្រឿងញៀន? | ☐ ភ័យខ្លាច<br>☐ ឆេវឆាយ<br>☐ រវើរវាយ<br>☐ ស្គមស្គាំង<br>☐ ដេកមិនលក់<br>☐ បាត់បង់ម្ចាស់ការលើខ្លួនឯង<br>☐ បង្ករហឹង្សាលើអ្នកដ៏ទៃ<br>☐ លួច ប្លន់<br>☐ ធ្វើអត្តឃាត (សម្លាប់ខ្លួនឯង)<br>☐ ផ្សេងៗ…………………………………… |
| S2Q8 | តើអ្នកដឹងថា គ្រឿងញៀនទាំងនោះ មានប្រភពមកពីណាឬទេ? | ☐ បាទ ចាស ☐ អត់ទេ (រំលងទៅ S3Q1) |
| S2Q9 | បើបាទ ឬ ចាស តើជាអ្នកណា? | ☐ មិនដឹង<br>☐ មិត្តភក្ររបស់គាត់<br>☐ បងប្អូន (ពូ មីង អ៊ំ ឪពុកម្តាយ បងប្អូនបង្កើត)<br>☐ អ្នកជិតខាងរបស់គាត់<br>☐ អាជ្ញាធរ (មេភូមិ ឃុំ ប៉ូលីស សន្តិសុខភូមិ)<br>☐ ជនមកពីខាងក្រៅ<br>☐ ផ្សេងៗ………………………………………. |
| **ផ្នែកទី ៣៖ សុវត្ថិភាពរបស់កុមារ** | | |
| S3Q1 | តើអ្នកខ្លាចមានគេណែនាំ ឬ លួងលោម ឬ បង្ខំឱ្យប្រើប្រាស់គ្រឿងញៀនឬទេ? | ☐ បាទ ចាស ☐ អត់ទេ |
| S3Q2 | តើអ្នកខ្លាចអ្នកប្រើប្រាស់គ្រឿងញៀនប្រព្រឹត្តអ្វីមួយមកលើអ្នកឬទេ? | ☐ បាទ ចាស ☐ អត់ទេ (រំលងទៅ S3Q4) |

| | | |
|---|---|---|
| S3Q3 | បើបាទ ឬ ចាស តើខ្លាចអ្វីខ្លះ? | ☐ អំពើហឹង្សា (វាយ សម្លុត គម្រាម)<br>☐ ធ្វើឃាត<br>☐ លួច ប្លន់<br>☐ ប្រព្រឹត្តពេស្យាចារ (រំលោភ)<br>☐ លួងលោម ឬ បង្ខំឱ្យប្រើថ្នាំញៀន<br>☐ ផ្សេងៗ………………………………………… |
| S3S4 | តើអ្នករងផលប៉ះពាល់អ្វីខ្លះដោយសារការប្រើប្រាស់គ្រឿងញៀនក្នុងសហគមន៍របស់អ្នក? | ☐ មិនមានផលប៉ះពាល់អ្វីទាំងអស់<br>☐ មិនហ៊ានទៅសាលារៀន<br>☐ មិនហ៊ានទៅរៀនមុខវិជ្ជាផ្សេងៗបន្ថែម<br>☐ បាត់បង់ឱកាសចូលរួមសកម្មភាពផ្សេងៗក្នុងសង្គម<br>☐ មិនហ៊ានធ្វើដំណើរទៅទីកន្លែងផ្សេងៗ<br>☐ មិនហ៊াននៅផ្ទះម្នាក់ឯង<br>☐ ផ្សេងៗ………………………………………… |
| S3Q5 | តើអ្នកធ្លាប់ត្រូវបានគេណែនាំ ឬ លួងលោម ឬ បង្ខំឱ្យប្រើប្រាស់គ្រឿងញៀនឬទេ? | ☐ បាទ ចាស ☐ អត់ទេ (រំលងទៅ S3Q7) |
| S3Q6 | បើបាទ ឬ ចាស តើអ្នកស្គាល់អ្នកដែលណែនាំអ្នកឬទេ? | ☐ មិនដឹង<br>☐ មិត្តភក្រ<br>☐ បងប្អូន (បងប្អូនបង្កើត ជីដូនមួយ)<br>☐ ពូ មីង ឬ អ៊ំ<br>☐ ឪពុកម្តាយ<br>☐ អ្នកជិតខាង<br>☐ អាជ្ញាធរ (មេភូមិ ឃុំ ប៉ូលីស សន្តិសុខភូមិ)<br>☐ ក្មេងទំនើង<br>☐ ផ្សេងៗ…………………………………………… |
| S3Q7 | តើអ្នកធ្លាប់ប្រើប្រាស់គ្រឿងញៀនឬទេ? | ☐ បាទ ចាស ☐ អត់ទេ (រំលងទៅ S4Q1) |
| S3Q8 | បើបាទ ឬ ចាស តើជាគ្រឿងញៀនប្រភេទអ្វីខ្លះ? | 1. ………………………………………….<br>2. ………………………………………… |
| S3Q9 | តើគ្រឿងទាំងនោះបានមកពីណា? | ☐ មិនដឹង<br>☐ មិត្តភក្រ<br>☐ បងប្អូន (បងប្អូនបង្កើត ជីដូនមួយ)<br>☐ ពូ មីង ឬ អ៊ំ<br>☐ ឪពុកម្តាយ<br>☐ អ្នកជិតខាង<br>☐ អាជ្ញាធរ (មេភូមិ ឃុំ ប៉ូលីស សន្តិសុខភូមិ)<br>☐ ផ្សេងៗ………………………………………… |

| ផ្នែកទី ៤៖ កិច្ចអន្តរាគមន៍ | | |
|---|---|---|
| S4Q1 | តើអ្នកធ្លាប់ឃើញអាជ្ញាធរមូលដ្ឋាន (មេភូមិ ឃុំ/សង្កាត់ ប៉ូលីស) ចុះអប់រំ និងផ្សព្វផ្សាយអំពីផលប៉ះពាល់ និងការបង្ការខ្លួនពីការប្រើប្រាស់ថ្នាំញៀនក្នុងសហគមន៍ដែលអ្នករស់នៅឬទេ? | ☐ បាទ ចាស ☐ អត់ទេ (រំលងទៅ S4Q4) |
| S4Q2 | បើបាទ ឬ ចាស តើការអប់រំ ផ្សព្វផ្សាយធ្វើឡើងដូចម្តេច? | ☐ ចុះបង្រៀនតាមភូមិ<br>☐ ការបិតផ្សាយជាក្រដាស ឬ ខិត្តបណ្ណ<br>☐ ការផ្សព្វផ្សាយដោយប្រើផ្ទាំងប៉ាណូធំៗ<br>☐ បញ្ច្រៀបក្នុងកម្មវិធីអប់រំផ្សេងៗ (ទិវាសិទ្ធិកុមារ..)<br>☐ ផ្សព្វផ្សាយតាមសាលារៀន<br>☐ ផ្សេងៗ…………………………………………………… |
| S4Q3 | តើអ្នកណាខ្លះជាអ្នកចុះអប់រំផ្សព្វផ្សាយ? | ☐ មេភូមិ<br>☐ បុគ្គលិក ឬ ក្រុមប្រឹក្សាឃុំ<br>☐ ប៉ូលីសប៉ុស្តិ៍<br>☐ ក្រុមកុមារ និងយុវជនស្មគ្រចិត្ត<br>☐ ផ្សេងៗ……………………………………………….. |
| S4Q4 | តើអ្នកធ្លាប់ឃើញអាជ្ញាធរមូលដ្ឋានចុះបង្ក្រាប ឬ ចាប់ខ្លួនអ្នកចែកចាយ ឬ ប្រើប្រាស់គ្រឿងញៀនឬទេ? | ☐ បាទ ចាស ☐ អត់ទេ (រំលងទៅ S5Q1) |
| S4Q5 | បើបាទ ឬ ចាស អាជ្ញាធរបានធ្វើអ្វីខ្លះចំពោះពួកគេ? | ☐ មិនដឹង<br>☐ មិនធ្វើអ្វីទាំងអស់ (ដោះលែង)<br>☐ អប់រំ ណែនាំ (មុនដោះលែង)<br>☐ ផាកពិន័យជាលុយកាក់<br>☐ បញ្ជូនទៅតុលាកា<br>☐ ដាក់ពន្ធនាគារ<br>☐ ផ្សេងៗ………………………………………………. |
| **ផ្នែកទី ៥៖ សំណូមពរ** | | |
| S5Q1 | តើអ្នកមានសំណូមពរអ្វីខ្លះ?<br>1. ......................................<br>2. ......................................<br>3. ......................................<br>4. ......................................<br>5. ......................................<br>6. ......................................<br>7. ...................................... | |

**ឯកសារភ្ជាប់ទី ២៖ ទម្រង់យល់ព្រមកុមារអ្នកចុះសម្ភាសន៍**

## <u>ទម្រង់ការយល់ព្រមរបស់កុមារ</u>
## ការស្ទង់មតិកុមារអំពីស្ថានភាពនៃការប្រើប្រាស់គ្រឿងញៀនក្នុងសហគមន៍

**ផ្នែកទី ១: អំពីអ្នកសម្ភាសន៍**

ខ្ញុំជាកុមារ/យុវជនស្ម័គ្រចិត្ត អង្គការហ្វូដណេបឺសកម្ពុជា កំពុងធ្វើការសិក្សាអំពីការយល់ដឹង និងស្ថានភាពនៃការប្រើប្រាស់គ្រឿងញៀនក្នុងសហគមន៍។ ខ្ញុំបាទ/នាងខ្ញុំ បានទទួលការបណ្តុះបណ្តាលចំណេះដឹងអំពីគ្រឿងញៀន ការបង្ការខ្លួន និងការចូលរួមទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀនក្នុងសហគមន៍របស់ខ្ញុំ ព្រមទាំងទទួលបានការសម្របសម្រួលអោយបង្កើតកម្រងសំណួរសម្រាប់សម្ភាសន៍ទាំងនេះដោយខ្លួនឯង តាមរយៈសិក្ខាសាលារយៈពេលពីរថ្ងៃនៅថ្ងៃទី៧ និង៨ ខែឧសភា ឆ្នាំ២០១៩។ ខ្ញុំយល់ច្បាស់ និងជឿជាក់ថា ការស្ម័គ្រចិត្តរបស់ខ្ញុំក្នុងការចុះធ្វើការស្ទង់មតិនេះ ពិតជាមានសារៈសំខាន់ និងបានចូលរួមក្នុងការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀនក្នុងសហគមន៍របស់ខ្ញុំអោយកាន់តែមានប្រសិទ្ធិភាព។

**ផ្នែកទី ១: អំពីកុមារដែលត្រូវបានសម្ភាសន៍**

ខ្ញុំបាទ/នាងខ្ញុំបានយល់ពីគោលបំណង និងយល់ព្រមចូលរួមការសម្ភាសន៍ដើម្បីផ្តល់ព័ត៌មានអំពីការយល់ដឹង បទពិសោធន៍ និងស្ថានភាពនៃការប្រើប្រាស់គ្រឿងញៀនក្នុងសហគមន៍របស់ខ្ញុំ។ ខ្ញុំជឿជាក់ថាការចូលរួមរបស់ខ្ញុំ គឺជាចំណែកមួយដ៏សំខាន់ដើម្បីទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀនក្នុងសាលារៀន និងសហគមន៍របស់ខ្ញុំឲ្យមានប្រសិទ្ធិភាព។ ខ្ញុំជឿជាក់ថា ព័ត៌មាននានាអំពីខ្ញុំ ដែលផ្តល់ឱ្យតាមរយៈការសម្ភាសន៍នេះ នឹងរក្សាទុកជាការសម្ងាត់ និងប្រើប្រាស់បានត្រឹមត្រូវ។

កាលបរិច្ឆេទ: ថ្ងៃទី............... ខែ............ ឆ្នាំ ២០១៩

ហត្ថលេខា និងឈ្មោះអ្នកសម្ភាសន៍ ហត្ថលេខា និងឈ្មោះកុមារដែលត្រូវសម្ភាសន៍

................................................ ...........................................................

**បានឃើញ យល់ពីគោលបំណង និងគាំទ្រលើសកម្មភាពនៃការសម្ភាសន៍នេះ**

ហត្ថលេខា និងឈ្មោះអ្នកទទួលស្គាល់ និងដឹងលឺ

................................................

តួនាទី:………………………………………………….

**ឯកសារភ្ជាប់ទី ៣៖ សេចក្តីណែនាំអំពីការចុះស្រាវជ្រាវដោយកុមារ**

## ទម្រង់ការយល់ព្រមរបស់កុមារ

## ការស្ទង់មតិកុមារអំពីស្ថានភាពនៃការប្រើប្រាស់គ្រឿងញៀនក្នុងសហគមន៍

**ផ្នែកទី ១: អំពីអ្នកសម្ភាសន៍**

ខ្ញុំជាកុមារ/យុវជនស្ម័គ្រចិត្ត អង្គការហ្វូដណេប៊ីសកម្ពុជា កំពុងធ្វើការសិក្សាអំពីការយល់ដឹង និងស្ថានភាពនៃការប្រើប្រាស់គ្រឿងញៀនក្នុងសហគមន៍។ ខ្ញុំបាទ/នាងខ្ញុំ បានទទួលការបណ្តុះបណ្តាលចំណេះដឹងអំពីគ្រឿងញៀន ការបង្ការខ្លួន និងការចូលរួមទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀនក្នុងសហគមន៍របស់ខ្ញុំ ព្រមទាំងទទួលបានការសម្របសម្រួលអោយបង្កើតកម្រងសំណួរសម្រាប់សម្ភាសន៍ទាំងនេះដោយខ្លួនឯង តាមរយៈសិក្ខាសាលារយៈពេលពីរថ្ងៃនៅថ្ងៃទី៧ និង៨ ខែឧសភា ឆ្នាំ២០១៩។ ខ្ញុំយល់ច្បាស់ និងជឿជាក់ថា ការស្ម័គ្រចិត្តរបស់ខ្ញុំក្នុងការចុះធ្វើការស្ទង់មតិនេះ ពិតជាមានសារៈសំខាន់ និងបានចូលរួមក្នុងការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀនក្នុងសហគមន៍របស់ខ្ញុំអោយកាន់តែមានប្រសិទ្ធិភាព។

**ផ្នែកទី ១: អំពីកុមារដែលត្រូវបានសម្ភាសន៍**

ខ្ញុំបាទ/នាងខ្ញុំបានយល់ពីគោលបំណង និងយល់ព្រមចូលរួមការសម្ភាសន៍ដើម្បីផ្តល់ព័ត៌មានអំពីការយល់ដឹង បទពិសោធន៍ និងស្ថានភាពនៃការប្រើប្រាស់គ្រឿងញៀនក្នុងសហគមន៍របស់ខ្ញុំ។ ខ្ញុំជឿជាក់ថាការចូលរួមរបស់ខ្ញុំ គឺជាចំណែកមួយដ៏សំខាន់ដើម្បីទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀនក្នុងសាលារៀន និងសហគមន៍របស់ខ្ញុំឲ្យមានប្រសិទ្ធិភាព។ ខ្ញុំជឿជាក់ថា ព័ត៌មាននានាអំពីខ្ញុំ ដែលផ្តល់ឱ្យតាមរយៈការសម្ភាសន៍នេះនឹងរក្សាទុកជាការសម្ងាត់ និងប្រើប្រាស់បានត្រឹមត្រូវ។

កាលបរិច្ឆេទ: ថ្ងៃទី............... ខែ............. ឆ្នាំ ២០១៩

ហត្ថលេខា និងឈ្មោះអ្នកសម្ភាសន៍ ហត្ថលេខា និងឈ្មោះកុមារដែលត្រូវសម្ភាសន៍

................................................ ..............................................................

**បានឃើញ យល់ពីគោលបំណង និងគាំទ្រលើសកម្មភាពនៃការសម្ភាសន៍នេះ**

ហត្ថលេខា និងឈ្មោះអ្នកទទួលស្គាល់ និងដឹងលឺ

................................................

តួនាទី:……………………………………………….

ឯកសារភ្ជាប់ទី ៤៖ សំណូមពរពីកុមារ

## សំណូមពរពីកុមារ

- សូមអោយមានការចុះផ្សព្វផ្សាយអំពីការបង្ការខ្លួនពីគ្រឿងញៀនតាមភូមិ ឃុំ និងសាលារៀនដើម្បីឱ្យយុវជន និងសិស្សានុសិស្សទាំងអស់បានយល់ពីផលប៉ះពាល់នៃគ្រឿងញៀនកាន់តែច្បាស់
- សូមអាជ្ញាធរចុះត្រួតពិនិត្យក្នុងសហគមន៍ដើម្បីបង្ក្រាបកុំឱ្យមានការជួញដូរ និងប្រើប្រាស់គ្រឿងញៀន។
- សូមមន្ត្រីប៉ូលីសចុះបង្រៀន និងត្រួតពិនិត្យនៅតាមភូមិ ឃុំ និងសាលារៀនឱ្យបានទៀងទាត់ដើម្បីធានាថាមិនមានការជួញដូរ និងការប្រើប្រាស់គ្រឿងញៀនក្នុងចំណោមសិស្សានុសិស្ស
- សូមមានការបិតជាផ្ទាំងប៉ាណូនៅតាមសាលារៀន និងកន្លែងផ្សេងៗទៀតក្នុងសហគមន៍ដើម្បីបង្កើនការយល់ដឹងដល់កុមារ និងអាណាព្យាបាលអំពីផលប៉ះពាល់នៃគ្រឿងញៀន
- សូមទប់ស្កាត់កុំអោយមានការហូរចូលនៃសារធាតុញៀន និងគ្រឿងញៀនក្នុងសាលារៀន និងសហគមន៍
- សូមអាជ្ញាធរចុះបង្ក្រាប និងចាប់អ្នកផលិត ជួញដូរ និងប្រើប្រាស់គ្រឿងញៀនឱ្យមានប្រសិទ្ធភាព និងតម្លាភាព
- សូមអាជ្ញាធរបង្កើនការចុះល្បាត និងសើបអង្កេតតាមភូមិ និងឃុំ-សង្កាត់អំពីបញ្ហាគ្រឿងញៀន
- សូមមានការចុះផ្សព្វផ្សាយបន្ថែមពីបញ្ហាគ្រឿងញៀន និងចុះត្រួតពិនិត្យសន្តិសុខនៅក្នុងសង្គម
- សូមអង្គការហ្វូដណេបឺសកម្ពុជាជួយបង្រៀនដល់កុមារ និងយុវជនក្នុងសហគមន៍អំពីបញ្ហាគ្រឿងញៀន
- កុមារ និងយុវជនខ្លួនឯងត្រូវស្វែងយល់បន្ថែម និងជៀសឱ្យឆ្ងាយពីគ្រឿងញៀន

ឯកសារភ្ជាប់ទី ៥៖ បញ្ជីរឈ្មោះកុមារ យុវជនចុះប្រមូលទិន្នន័យ

## បញ្ជីរឈ្មោះកុមារ និងយុវជនចុះប្រមូលទិន្នន័យ

| លរ | ឈ្មោះ | ភេទ | តួនាទី | ស្រុក-ខណ្ឌ ខេត្ត-រាជធានី |
|---|---|---|---|---|
| ១ | វ៉ា វ៉ាន់ | ស | ប្រធាន | ស្រុកអូជ្រៅ ខេត្តបន្ទាយមានជ័យ |
| ២ | ណាន ស្រីនាថ | ស | អនុប្រធាន | ស្រុកអូជ្រៅ ខេត្តបន្ទាយមានជ័យ |
| ៣ | វ៉ាន់ លីហេង | ស | ប្រធាន | ស្រុកអូជ្រៅ ខេត្តបន្ទាយមានជ័យ |
| ៤ | អ៊ុន ស្រីម៉ុច | ស | បេឡា | ស្រុកអូជ្រៅ ខេត្តបន្ទាយមានជ័យ |
| ៥ | សួយ វុទ្ធី | ប | ប្រធាន | ស្រុកអូជ្រៅ ខេត្តបន្ទាយមានជ័យ |
| ៦ | ផុន ក្តឹប | ប | អនុប្រធាន | ស្រុកអូជ្រៅ ខេត្តបន្ទាយមានជ័យ |
| ៧ | ឆឹន អ៊ីលីណា | ស | អរិញ្ញិក | ស្រុកអូជ្រៅ ខេត្តបន្ទាយមានជ័យ |
| ៨ | សឹង សុវណ្ណារី | ស | សមាជិក | ស្រុកអូជ្រៅ ខេត្តបន្ទាយមានជ័យ |
| ៩ | អេប វណ្ណនី | ស | ប្រធាន | ស្រុកអូជ្រៅ ខេត្តបន្ទាយមានជ័យ |
| ១០ | យុន លក្ខាវណ្ណ | ស | ហិរញ្ញិក | ស្រុកអូជ្រៅ ខេត្តបន្ទាយមានជ័យ |
| ១១ | រៀម ស្រីហុន | ស | ប្រធាន | ស្រុកថ្មគោល ខេត្តបាត់ដំបង |
| ១២ | ហឿត ស្រីលីស | ស | ប្រធាន | ស្រុកថ្មគោល ខេត្តបាត់ដំបង |
| ១៣ | ផុន ស្រមោចក្រហម | ស | ប្រធាន | ស្រុកឯកភ្នំ ខេត្តបាត់ដំបង |
| ១៤ | នៅ ស៊ីវន | ស | ប្រធាន | ស្រុកឯកភ្នំ ខេត្តបាត់ដំបង |
| ១៥ | ផុន យ៉ាវ៉ាន់ | ស | ប្រធាន | ស្រុកឯកភ្នំ ខេត្តបាត់ដំបង |
| ១៦ | ថុល ប្រាក់ចាន់ | ស | សមាជិក | ស្រុកឯកភ្នំ ខេត្តបាត់ដំបង |
| ១៧ | រិទ្ធ រដ្ឋា | ស | ប្រធាន | ស្រុកឯកភ្នំ ខេត្តបាត់ដំបង |
| ១៨ | ផាត សុភ័ស្ត | ស | អនុប្រធាន | ស្រុកស្នួល ខេត្តក្រចេះ |
| ១៩ | ព្រិច ផាច | ស | ប្រធាន | ស្រុកស្នួល ខេត្តក្រចេះ |
| ២០ | ហ៊ាន សេងហ៊ួរ | ប | សមាជិក | ស្រុកស្នួល ខេត្តក្រចេះ |
| ២១ | សាត ពិសី | ស | សមាជិក | ស្រុកស្នួល ខេត្តក្រចេះ |
| ២២ | តុន ស្រីទៀង | ស | ប្រធាន | ស្រុកកោះញែក ខេត្តមណ្ឌលគិរី |
| ២៣ | វេន សុខនាង | ស | សមាជិក | ស្រុកកោះញែក ខេត្តមណ្ឌលគិរី |

| | | | | |
|---|---|---|---|---|
| ២៤ | ធន់ អន្តរៈ | ប | សមាជិក | ស្រុកកោះញែក ខេត្តមណ្ឌលគិរី |
| ២៥ | ហឿង សីហួ | ប | សមាជិក | ស្រុកកោះញែក ខេត្តមណ្ឌលគិរី |
| ២៦ | ណី ស្រីណុច | ស | សមាជិក | ស្រុកកោះញែក ខេត្តមណ្ឌលគិរី |
| ២៧ | ថេន ពិសី | ស | សមាជិក | ស្រុកកោះញែក ខេត្តមណ្ឌលគិរី |
| ២៨ | ប៊ុនគីសុខគ័ង | ស | សមាជិក | ស្រុកកោះញែក ខេត្តមណ្ឌលគិរី |
| ២៩ | ឈិន វណ្ណដេត | ស | សមាជិក | ស្រុកកោះញែក ខេត្តមណ្ឌលគិរី |
| ៣០ | សុខ សែត | ប | ប្រធាន | ស្រុកកោះញែក ខេត្តមណ្ឌលគិរី |
| ៣១ | ម៉ី ស្រីទៀង | ស | សមាជិក | ស្រុកកោះញែក ខេត្តមណ្ឌលគិរី |
| ៣២ | ណូត លូល | ប | សមាជិក | ស្រុកកោះញែក ខេត្តមណ្ឌលគិរី |
| ៣៣ | វិបុល បូណា | ប | សមាជិក | ខណ្ឌដង្កោរ រាជធានីភ្នំពេញ |
| ៣៤ | អាន សុខស្រីលាភ | ស | សមាជិក | ខណ្ឌដង្កោរ រាជធានីភ្នំពេញ |
| ២៥ | សួង សេរីវឌ្ឍនា | ប | ប្រធាន | ខណ្ឌដង្កោរ រាជធានីភ្នំពេញ |
| ៣៦ | គង់ ច័ន្ទមុន្នីកែវ | ស | ប្រធាន | ខណ្ឌដង្កោរ រាជធានីភ្នំពេញ |
| ៣៧ | រិន ណងគា | ស | ប្រធាន | ខណ្ឌដង្កោរ រាជធានីភ្នំពេញ |
| ៣៨ | រិន ទិត្យារក្ស | ប | ប្រធាន | ខណ្ឌដង្កោរ រាជធានីភ្នំពេញ |
| ៣៩ | ឃៀង ចន្ទកនិកា | ស | សមាជិក | ខណ្ឌដង្កោរ រាជធានីភ្នំពេញ |
| ៤០ | ឃី ឧត្តម | ប | ប្រធាន | ខណ្ឌដង្កោរ រាជធានីភ្នំពេញ |